របាយការណ៍ព័ត៌មានស្តីអំពីថ្នាំបង្ការ

# ថ្នាំបង្ការជំងឺគ្រុនពោះវៀន

## *អ្វីដែលអ្នកត្រូវការដឹង*

របាយការណ៍ព័ត៌មានស្តីអំពីថ្នាំបង្ការជាច្រើនមានជាភាសាអេស្ប៉ាញនិងភាសាដទៃទៀត។
សូមមើលនៅក្នុងគេហទំព័រ www.immunize.org/vis

## 1 តើថ្នាំបង្ការជំងឺគ្រុនពោះវៀនជាអ្វី?

ជំងឺគ្រុនពោះវៀនគឺជាជំងឺធ្ងន់ធ្ងរ។ វាបង្កឡើងដោយបាក់តេរីដែលមានឈ្មោះថា *Salmonella* Typhi ។

ជំងឺគ្រុនពោះវៀនបង្កឲ្យមានគ្រុនក្តៅខ្ពស់ ល្វិតល្វៃ អស់កំលាំង ឈឺពោះ ឈឺក្បាល មិនឃ្លានអាហារ និងពេលខ្លះមានឡើងកន្ទួលរោល លើស្បែក ។ ប្រសិនបើមិនព្យាបាលទេនោះ វាអាចសំលាប់មនុស្សរហូត ដល់ 30% ដែលមានជំងឺនេះ។

មនុស្សមួយចំនួនដែលកើតជំងឺគ្រុនពោះវៀនបានក្លាយជា"អ្នកផ្ទុក"ដែលអាចចំលងជំងឺនេះទៅកាន់អ្នកដទៃទៀតបាន។

ជាទូទៅ មនុស្សកើតជំងឺគ្រុនពោះវៀនពីអាហារឬទឹកមិនស្អាត។ គ្រុនពោះវៀនកំរកើតមានណាស់នៅសហរដ្ឋអាមេរិក ហើយពលរដ្ឋអាមេរិក សឹងគ្រប់រូបដែលកើតជំងឺនេះ កើតនៅខណៈពេលដែលគេធ្វើដំណើរ។

ជំងឺគ្រុនពោះវៀនវាយប្រហារប្រជាជនប្រហែល 21 លាននាក់ក្នុងមួយឆ្នាំនៅទូទាំងពិភពលោកហើយសំលាប់មនុស្សប្រហែល 200 000 នាក់។

## 2 ថ្នាំបង្ការជំងឺគ្រុនពោះវៀន

ថ្នាំបង្ការជំងឺគ្រុនពោះវៀនអាចបង្ការជំងឺគ្រុនពោះវៀនបាន។

មានថ្នាំបង្ការពីរយ៉ាងដើម្បីបង្ការជំងឺគ្រុនពោះវៀន។ មួយប្រភេទគឺជាថ្នាំបង្ការអសកម្ម (ស្លាប់)ដែលត្រូវបានទទួលក្នុងលក្ខណៈជាថ្នាំចាក់។ មួយប្រភេទទៀតគឺថ្នាំបង្ការប្រភេទរស់ បន្ថយឥទ្ធិពល (បន្សាយ) ដែលត្រូវបានយកមកប្រើប្រាស់ដោយលេប (តាមមាត់)។

## 3 នរណាគួរទទួលថ្នាំបង្ការជំងឺគ្រុនពោះវៀនហើយទទួលនៅពេលណា?

ការផ្តល់ថ្នាំបង្ការជំងឺគ្រុនពោះវៀនជាប្រចាំមិនត្រូវបានគេណែនាំជាអនុសាសន៍ឡើយនៅសហរដ្ឋអាមេរិក ប៉ុន្តែថ្នាំបង្ការជំងឺគ្រុនពោះវៀនត្រូវបានណែនាំជាអនុសាសន៍សំរាប់៖

- អ្នកដំណើរទៅកាន់ផ្នែកនៃពិភពលោកដែលជំងឺគ្រុនពោះវៀនឃើញកើតមានជាញឹកញាប់។ (កំណត់សំគាល់៖ ថ្នាំបង្ការជំងឺគ្រុនពោះវៀនមិនមានប្រសិទ្ធិភាព 100% ឡើយហើយមិនអាចជំនួសឲ្យការប្រុងប្រយ័ត្នចំពោះអ្វីដែលអ្នកបរិភោគឬផឹកនោះឡើយ)។
- អ្នកដែលស្ថិតនៅជិតដិតស្និទ្ធិស្នាលនឹងអ្នកផ្ទុកមេរោគគ្រុនពោះវៀន។
- បុគ្គលិកបំរើការក្នុងមន្ទីរពិសោធន៍ដែលធ្វើការជាមួយបាក់តេរី *Salmonella* Typhi ។

**ថ្នាំបង្ការជំងឺគ្រុនពោះវៀនអសកម្ម (ថ្នាំបង្ការប្រភេទចាក់)**

- ថ្នាំបង្ការមួយកំរិតផ្តល់នូវការពារបាន។ វាគួរត្រូវបានផ្តល់ជូននៅពេលយ៉ាងហោចណាស់ 2 សប្តាហ៍មុនពេលធ្វើដំណើរដើម្បីអនុញ្ញាត្តិឲ្យថ្នាំបង្ការមានពេលដើម្បីមានប្រសិទ្ធិភាព។
- កំរិតថ្នាំបង្ការសំរាប់រំលឹកគឺចាំបាច់នៅរៀងរាល់ពីរឆ្នាំម្តងសំរាប់អ្នកទាំងឡាយណាដែលនៅតែប្រឈមនឹងគ្រោះថ្នាក់។

**ថ្នាំបង្ការជំងឺគ្រុនពោះវៀនប្រភេទរស់ (ថ្នាំបង្ការប្រភេទលេប)**

- កំរិតថ្នាំបង្ការចំនួនបួនដង៖ មួយគ្រាប់ប្រើមួយថ្ងៃខានមួយថ្ងៃក្នុងរយៈពេលមួយសប្តាហ៍ (ថ្ងៃទី 1, ថ្ងៃទី 3, ថ្ងៃទី 5, និងថ្ងៃទី 7)។
  កំរិតថ្នាំបង្ការចុងក្រោយគួរតែផ្តល់ឲ្យយ៉ាងហោចណាស់ 1 សប្តាហ៍មុនការ
  ធ្វើដំណើរដើម្បីអនុញ្ញាត្តិឲ្យថ្នាំបង្ការមានពេលដើម្បីមានប្រសិទ្ធិភាព។
- លេបចូលកំរិតថ្នាំបង្ការនីមួយៗប្រហែលមួយម៉ោងមុនអាហារជាមួយ នឹងទឹកត្រជាក់ឬទឹកដែលមានកំដៅធម្មតា។
  *សូមកុំទំពារគ្រាប់ថ្នាំបង្ការ។*
- កំរិតថ្នាំបង្ការសំរាប់រំលឹកគឺត្រូវការចាំបាច់នៅរៀងរាល់ 5 ឆ្នាំសំរាប់អ្នកដែលនៅប្រឈមនឹងគ្រោះថ្នាក់។

ថ្នាំបង្ការណាមួយទាំងពីរយ៉ាងនេះអាចនឹងត្រូវបានផ្តល់ឲ្យប្រកបដោយសុវត្ថិភាពក្នុងពេលព្រមគ្នាជាមួយថ្នាំបង្ការដទៃទៀត។

## 4 មនុស្សខ្លះមិនគួរទទួលថ្នាំបង្ការជំងឺគ្រុនពោះវៀនឬគួរពន្យារពេលរង់ចាំសិន

**ថ្នាំបង្ការជំងឺគ្រុនពោះវៀនអសកម្ម (ថ្នាំបង្ការប្រភេទចាក់)**

- មិនគួរផ្តល់ឲ្យកុមារអាយុតិចជាង 2 ឆ្នាំ។
- គ្រប់គ្នាដែលមានប្រតិកម្មធ្ងន់ធ្ងរទៅនឹងកំរិតថ្នាំបង្ការពីពេលមុនមិនគួរទទួលកំរិតថ្នាំបង្ការម្តុ
- គ្រប់គ្នាដែលមានអាលែកហ្ស៊ីធ្ងន់ធ្ងរទៅនឹងសមាសធាតុផ្សំណាមួយនៃថ្នាំបង្ការនេះមិនគួរទទួលវាឡើយ។
  សូមប្រាប់វេជ្ជបណ្ឌិតអ្នកប្រសិនបើអ្នកមានអាលែកហ្ស៊ីធ្ងន់ធ្ងរអ្វីមួយ។
- គ្រប់គ្នាដែលមានជំងឺកំរិតមធ្យមឬធ្ងន់ធ្ងរនៅពេលថ្នាំបង្ការត្រូវបានគេរៀបចំកំណត់ពេលផ្តល់ជាធម្មតាគួរតែរង់ចាំរហូតដល់ពួកគេបានសះស្បើយមុនពេលវា។

**ថ្នាំបង្ការជំងឺគ្រុនពោះវៀនប្រភេទរស់ (ប្រើដោយលេប)**

- មិនគួរផ្តល់ជូនកុមារអាយុតិចជាង 6 ឆ្នាំឡើយ។
- គ្រប់គ្នាដែលមានប្រតិកម្មធ្ងន់ធ្ងរទៅនឹងកំរិតថ្នាំបង្ការពីពេលមុនមិនគួរទទួលកំរិតថ្នាំបង្ការម្តងទៀតទេ។
- គ្រប់គ្នាដែលមានអាលែកហ្ស៊ីធ្ងន់ធ្ងរទៅនឹងសមាសធាតុផ្សំណាមួយនៃថ្នាំបង្ការនេះមិនគួរទទួលវាឡើយ។
  សូមប្រាប់វេជ្ជបណ្ឌិតអ្នកប្រសិនបើអ្នកមានអាលែកហ្ស៊ីធ្ងន់ធ្ងរអ្វីមួយ។
- គ្រប់គ្នាដែលមានជំងឺកំរិតមធ្យមឬធ្ងន់ធ្ងរនៅពេលដែលថ្នាំបង្ការត្រូវបានគេរៀបចំកំណត់ពេលផ្តល់ជាធម្មតាគួររង់ចាំរហូតដល់ពួកគេបានសះស្បើយមុនពេលទទួលវា។ សូមប្រាប់វេជ្ជបណ្ឌិតអ្នកប្រសិនបើអ្នកមានជំងឺពាក់ព័ន្ធនឹងការក្អួតឬរាគរូស។



U.S. Department of Health and Human Services
Centers for Disease Control and Prevention

- គ្រប់គ្នាដែលប្រព័ន្ធភាពស៊ាំរបស់ខ្លួនចុះខ្សោយមិនគួរទទួលថ្នាំបង្ការនេះទេ។ ពួកគេគួរទទួលថ្នាំបង្ការជំងឺគ្រុនពោះវៀនប្រភេទចាក់វិញ។ ចំនុចនេះរួមបញ្ចូលអ្នកទាំងឡាយណាដែល:
  - មានផ្ទុកមេរោគហ៊ីវ/អេដស៍ឬជំងឺមួយផ្សេងទៀតដែលមានឥទ្ធិពលប៉ះពាល់ដល់ប្រព័ន្ធភាពស៊ាំ,
  - កំពុងត្រូវបានព្យាបាលដោយឱសថដែលមានឥទ្ធិពលប៉ះពាល់ដល់ប្រព័ន្ធភាពស៊ាំ ដូចជាពពួក Steroid អស់រយៈពេល 2 សប្តាហ៍ឬវែងជាងនេះ,
  - មានជំងឺមហារីកប្រភេទណាក៏ដោយ,
  - កំពុងទទួលប្រើប្រាស់ការព្យាបាលជំងឺមហារីកដោយកាំរស្មីឬដោយឱសថ។
- ថ្នាំបង្ការជំងឺគ្រុនពោះវៀនប្រើលេបតាមមាត់មិនគួរផ្តល់ជូនឡើយរហូតទាល់តែយ៉ាងហោចណាស់ក៏ 3 ថ្ងៃដែរបន្ទាប់ពីប្រើប្រាស់ថ្នាំផ្សះប្រភេទខ្លះ។

សាកសួរវេជ្ជបណ្ឌិតអ្នកដើម្បីបានព័ត៌មានបន្ថែម។

## 5 តើអ្វីខ្លះជាគ្រោះថ្នាក់ពីថ្នាំបង្ការជំងឺគ្រុនពោះវៀន?

ដូចទៅនឹងឱសថគ្រប់មុខទូទៅដែរ, ថ្នាំបង្ការអាចបង្កនូវបញ្ហាធ្ងន់ធ្ងរដូចជាប្រតិកម្មអាលែកហ្ស៊ីធ្ងន់ធ្ងរ។
គ្រោះថ្នាក់នៃថ្នាំបង្ការជំងឺគ្រុនពោះវៀន បង្កនូវទុក្ខទោសធ្ងន់ធ្ងរឬការស្លាប់ គឺមានតិចតួចយ៉ាងខ្លាំង។
បញ្ហាធ្ងន់ធ្ងរមកពីថ្នាំបង្ការណាមួយនៃប្រភេទទាំងពីរគឺកំរមានណាស់។

**ថ្នាំបង្ការជំងឺគ្រុនពោះវៀនអសកម្ម (ថ្នាំបង្ការប្រភេទចាក់)**

*ប្រតិកម្មកំរិតស្រាល*

- គ្រុនក្តៅ (មានរហូតដល់ប្រហែល 1 នាក់ក្នុងចំណោមមនុស្ស 100 នាក់)
- ឈឺក្បាល (មានរហូតដល់ប្រហែល 1 នាក់ក្នុងចំណោមមនុស្ស 30 នាក់)
- ឡើងក្រហមឬហើមនៅត្រង់កន្លែងចាក់ (មានរហូតដល់ប្រហែល 1 នាក់ក្នុងចំណោមមនុស្ស 15 នាក់)

**ថ្នាំបង្ការជំងឺគ្រុនពោះវៀនប្រភេទរស់ (ប្រើដោយលេប)**

*ប្រតិកម្មកំរិតស្រាល*

- គ្រុនក្តៅឬឈឺក្បាល (មានរហូតដល់ប្រហែល 1នាក់ក្នុងចំណោមមនុស្ស 20 នាក់)
- ឈឺពោះ, ចង្អោរ, ក្អួត, ឡើងរោលកន្ទួលស្បែក (កំរមាន)

## 6 ចុះបើមានប្រតិកម្មធ្ងន់ធ្ងរវិញ?

**តើខ្ញុំគួរស្វែងរកអ្វី?**

- ស្វែងរកនូវអ្វីដែលធ្វើឲ្យអ្នកមានការបារម្ភ ដូចជាសញ្ញានៃប្រតិកម្មអាលែកហ្ស៊ីធ្ងន់ធ្ងរ, គ្រុនក្តៅ ខ្ពស់យ៉ាងខ្លាំង, ឬបំលាស់ប្តូរអាកប្បកិរិយា។
សញ្ញានៃប្រតិកម្មអាលែកហ្ស៊ីធ្ងន់ធ្ងរអាចរួមមាន ការឡើងហើមកន្ទួលស្បែក, ហើមមុខនិងបំពង់ក, ពិបាកដកដង្ហើម, ចង្វាក់បេះដូងញាប់, វិលមុខ និងខ្សោយកំលាំង។
សញ្ញាទាំងនេះគួរតែចាប់ផ្តើមមានឡើងតែប៉ុន្មាននាទីរហូតដល់ប៉ុន្មានម៉ោងប៉ុណ្ណោះបន្ទាប់ពីការផ្តល់ថ្នាំបង្ការ រួច។

**តើខ្ញុំគួរធ្វើអ្វីខ្លះ?**

- ប្រសិនបើអ្នកគិតថាវាជាប្រតិកម្មអាលែកហ្ស៊ីធ្ងន់ធ្ងរឬស្ថានភាពបន្ទាន់ដទៃទៀតដែលអ្នកមិន អាចពន្យារពេលរង់ចាំបាន, សូមទូរស័ព្ទទៅកាន់លេខ 9-1-1 ឬយកមនុស្សនោះទៅកាន់មន្ទីរពេទ្យនៅជិតបំផុត។ មិនដូច្នោះទេ, សូមទូរស័ព្ទរកវេជ្ជបណ្ឌិតរបស់អ្នក។
- បន្ទាប់មក ប្រតិកម្មនោះគួរតែរាយការណ៍ជូនទៅ "ប្រព័ន្ធរាយការណ៍ពីហេតុភេទមិនល្អរបស់ ថ្នាំបង្ការ" (VAERS)។ វេជ្ជបណ្ឌិតអ្នកអាចនឹងរក្សាទុកជាឯកសារនូវរបាយការណ៍នេះ ឬអ្នកអាច ធ្វើវាដោយខ្លួនឯងតាមរយៈគេហទំព័រ VAERS: **www.vaers.hhs.gov** ឬដោយទូរស័ព្ទទៅកាន់ លេខ **1-800-822-7967**។

*VAERS គឺសំរាប់តែរាយការណ៍ពីប្រតិកម្មប៉ុណ្ណោះ។ គេមិនផ្តល់នូវដំបូន្មានផ្នែកវេជ្ជសាស្ត្រ ឡើយ។*

## 7 តើខ្ញុំស្វែងយល់បន្ថែមយ៉ាងដូចម្តេច?

- សាកសួរវេជ្ជបណ្ឌិតរបស់អ្នក។
- ទាក់ទងទៅកាន់មជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺ (CDC):
  - ទូរស័ព្ទទៅលេខ **1-800-232-4636 (1-800-CDC-INFO)** ឬ
  - ចូលទៅកាន់គេហទំព័រ CDC នៅ **www.cdc.gov/vaccines/vpd-vac/typhoid/default.htm**

Vaccine Information Statement

# Typhoid Vaccine

Khmer

5/29/2012

Translation provided by the California Department of Public Health